ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : ដងទង់

ភូមិ : ដងទង់

ឃុំ : កោះថ្កូវ

ស្រុក : ជលគិរី

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : ដងទង់

ភូមិ : ដងទង់

ឃុំ : កោះថ្កូវ

ស្រុក : ជលគីរី

ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **ដងទង់** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១៩** ខែ **មិថុនា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **ដងទង់** មានទីតាំងស្ថិតនៅក្នុងភូមិ **ដងទង់** ឃុំ **កោះថ្កូវ** ស្រុក **ជលគីរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **២១៥** នាក់ ស្រីចំនួន **១១២** នាក់ និងមានគណៈកម្មការចំនួន **៩** នាក់ ស្រីចំនួន **២** នាក់។ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន **៧៣** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួន រួមមានៈ

១- ធ្វើពង្រាងលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

២- ធ្វើផែនទីកន្លែងនេសាទសហគមន៍

៣- ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

៤- ចុះបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ

៥- ធ្វើការល្បាតនៅក្នុងដែនកន្លែងនេសាទសហគមន៍

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **៥២៨** នាក់ ប្រុស **២៧៣** នាក់ ស្រី **២៥៥** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **៥២៨** នាក់ ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាមចំនួន **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១០ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១០ នាក់ ស្រី ៣ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៦ នាក់ ស្រី ៤ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៤០ នាក់ ស្រី ២០ នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ៤ នាក់ ស្រី ៣ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាមប្រមាណ **គ្មាន** សាសនាកាតូលិកប្រមាណ **គ្មាន**។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **៩** នាក់ ស្រី ៩ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **១៥០** នាក់ ស្រី **៧០** នាក់ កំរិតមធ្យមសិក្សាចំនួន **៥០** នាក់ ស្រី **២០** នាក់

និងកិរិតថ្នាក់ឧត្តមសិក្សាចំនួន **៣** នាក់ ស្រី **គ្មាន**។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើនេសាទចំនួន ៦៣ គ្រួសារ
- ធ្វើស្រែប្រាំងចំនួន ៨៦ គ្រួសារ ទំហំ ១០៨ ហិកតា
- ដាំបន្លែចំនួន ៨០ គ្រួសារ ទំហំ ៦,៤០ ហិកតា
- ចិញ្ចឹមត្រីចំនួន ១០ គ្រួសារ
- ជាងផ្ទះចំនួន ៥ គ្រួសារ
- ដាំពោតចំនួន ៤០ គ្រួសារ ទំហំ ២,៤ ហិកតា
- លក់ដូរចំនួន ៥ គ្រួសារ
- កែច្នៃផលនេសាទចំនួន ៥៧ គ្រួសារ
- រត់ទូកដរចំនួន ៣ គ្រួសារ
- កាត់ដេរចំនួន ៥៤ គ្រួសារ
- កម្មករចំនួន ៨ នាក់
- ម៉ាស៊ីនបោកស្រូវចំនួន ៣ គ្រួសារ

**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍ **ជងចង់** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ ១៩ ដែននេសាទ ទឹកសាប ។ កន្លែងនេសាទសហគមន៍ **ជងចង់** មានទំហំ **២៧០** ហិកតា និង មានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹង **សហគមន៍នេសាទតាមល់ក្រោម**
- ខាងត្បូងទល់នឹង **សហគមន៍នេសាទស្តីបន្ទិច**
- ខាងកើតទល់នឹង **ពាក់កណ្តាលបឹងតាអោន និង បឹងដៃទាល់**
- ខាងលិចទល់នឹង **ទន្លេកប៉ាល់ (ជងចង់)**

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍ **ជងចង់** មានបឹងចំនួន **១** ព្រែកមានចំនួន **១** អូរមានចំនួន **៣** ស្រះមានចំនួន **១១** និង មេទឹកចំនួន **១**។

- បឹងឈ្មោះ **បឹងជងចង់** ទំហំ ១.០០០ម x ៥០ម ពុំធ្វើនេសាទ ព្រោះគោកនៅខែប្រាំង

- ព្រែកឈ្មោះ **ព្រែកដើមស្រល់** ទំហំ ១២០ម x ២០ម ពុំធ្វើនេសាទ ព្រោះជាច្រកចេញចូល
- អូរឈ្មោះ **អូរផ្លូវក្របី** ទំហំ ១.០០០ម x ៨ម ពុំធ្វើនេសាទ ព្រោះជាច្រកចេញចូល
- អូរឈ្មោះ **អូរដៃចម** ទំហំ ៧០០ម x ៥ម ពុំធ្វើនេសាទ ព្រោះជាច្រកចេញចូល
- អូរ **ដៃត្រពាំងព្រះធាតុ** ទំហំ ១.៥០០ម x ៧ម ពុំធ្វើនេសាទ ព្រោះជាច្រកចេញចូល
- មេទឹក **ក្អាក់** ទំហំ ៥ ហិកតា ស្តុកទឹកសំរាប់ស្រែប្រាំង

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹងឈ្មោះ **បឹងក្អាក់** ទំហំ ២.៥០០ម² (បណ្តោយ ៥០ម ទទឹង ៥០ម)

**ឃ. ធនធានផលផល**

- ប្រភេទត្រី :

  ១- ប្រភេទត្រីដែលកើនឡើង : ត្រីក្រុសខ្នងវែង ជន្ទាស់ភ្លក់ កញ្ចុះ ឆ្ពោក កំភ្លាញ ច្រកែង រៀល ផ្ទោង ក្រាញ់ កន្ទ្រប់ ឆ្លាំង ស្រកាវក្ហម ឆ្ពិន និងសង្កត់ប្រាក់។

  ២- ប្រភេទត្រីដែលមិនកើន មិនថយ : ត្រីអណ្តែង និង ខ្ទាន់។

  ៣- ប្រភេទត្រីដែលមានការថយចុះ : ត្រីស្លាត រស់ ក្រពាត់ សណ្តាយ តាអោន ក្រម៉ម ក្រាយ ត្រីគ្រុំ ឆ្ពោក ក្អែក ឆ្លូញ និង ខ្ញឹង។

- ប្រភេទវារីសត្វ : ពស់ ក្តាម កំពិស អន្ទង ខ្មៅ ខ្យង គ្រុំ លាស ឆ្លើង កង្កែប គីង្គក់ ហ៊ីង។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ : ដើមរាំង ត្រស់ ច្រកែង ត្រសេក ភ្នំភ្លើង អញ្ចាញ ខ្ទុម ដង្ក្បែកក្តាម បន្លាយួន ថ្កូវ អូយម៉ូយ ទន្លា ថ្វាន់ អាញៀវ រងា បបួយ បបុស ត្រែង ថ្មើមអណ្តើក បន្លាស្អិត ភ្អែកព្រាប ធ្មុងកញ្ចុះ ក្រ សាច់ប៉ូវ វល្លិដូងព្រះ វល្លិព្រេង ស្លត វល្លិជុយ វល្លិតាអើក អាវក្រពើ វល្លិសាវម៉ាវ សំរ៉ក ខ្ទាយមាន់ ស្វាព្រាម ផ្តៅល ញ ប៉ធិញញី ប៉ធិញឈ្មោល កណ្តាប់ចង្អេរ រំចង់ ព្រលិត សារាយ កន្ទាំងហៃ កំពឹងពួយ កំប្លោក ស្តុន ក្រចាប់ ជន្ទល់ភ្នំ ត្រាវគាត ស្មៅសក់សេះ កក់ជ្រុង ត្រណោតអន្ទុង ស្រង៉ៃ ស្មៅយីប៉ូង ស្មៅចិញ្ចៀន ស្មៅជើងក្រាស់ ប្រកផ្លែ ទឹកដោះខ្លា បន្លាបង្ក្រាប និង ប្រចៅព្រៃ។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន **១៨០** នាក់ ស្រី **៧០** នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន **២៣០** នាក់ ស្រី **៥០** នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន **៣០** នាក់ ស្រី **១០** នាក់

## ៦. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ...ដល់ ខែ....) |
|---|---|---|---|---|
| មង | ដៃ | ១០០ | ៨០០០ម | ខែ សីហា ដល់ខែ វិច្ឆិកា |
| សន្ទូចរនង | សាង | ១០ | ២០០០ ផ្លែ | ខែ កញ្ញា ដល់ខែ វិច្ឆិកា |
| សន្ទូចបង្កៃ | គ្រឿង | ២៥០ | ២៥០ ផ្លែ | ខែ មករា ដល់ខែ កុម្ភៈ |
| សៃយ៉ឺនកំពិស | គ្រឿង | ១០០ | ១០០ សៃយ៉ឺន | ខែ កញ្ញា ដល់ខែ តុលា |
| លប | គ្រឿង | ៥០ | ៥០ លប | ខែ កក្កដា ដល់ខែ សីហា |
| សំណាញ់ | គ្រឿង | ៤ | ៤ សំណាញ់ | ខែ មេសា ដល់ខែ ឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកត្នោត | ៣ | ១០០ គក្រ | |
| ទូកឈើ | ៨០ | ៣០០ គក្រ | |
| កាណូត | ១៣ | ៥០០ គក្រ- ១ ត | ១០-១៥ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ដៃ | ៨០ | ៦.៤០០ ម |
| សន្ទូចរនង | សាង | ៤០ | ១២.០០០ ផ្លែ |
| សន្ទូចបង្កៃ | គ្រឿង | ៥០០ | ៥០០ ផ្លែ |
| សំណាញ់ | គ្រឿង | ៥ | ៥ សំណាញ់ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកឈើ | ៣០ | ៣០០ គក្រ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ដៃ | ១២០ | ៩.៦០០ ម |
| សន្ទូចរនង | សាង | ១៥០ | ៤៥.០០០ ផ្លែ |

| | | | |
|---|---|---|---|
| សន្ទូចបង្កៃ | គ្រឿង | ១.៥០០ | ១.៥០០ ផ្លែ |
| សំណាញ់ | វង់ | ៣០ | ៣០ វង់ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកត្នោត | ៥ | ១០០ គក្រ | |
| ទូកឈើ | ៣ | ៣០០ គក្រ | |
| កាណូត | ២០ | ៣០០ គក្រ | ៥-៧ |

**គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក្រ)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៦០ គក្រ | ៨០ គក្រ | ១៤០ គក្រ/គ្រួសារ |
| ក្តាម ខ្យង | ២០ គក្រ | ៣០ គក្រ | ៥០ គក្រ/គ្រួសារ |
| កំពិស | ២០ គក្រ | ៤៥ គក្រ | ៦៥ គក្រ/គ្រួសារ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **ជងទង់** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវជំនោរឡើង និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (គ្រឿង/ វង់/ផ្ទៃដៃ) | |
| | ខែ តុលា ដល់ខែ មិនា | មង | ៩៦០០ ម | ១២០ | |
| | ខែ កញ្ញា ដល់ខែ វិច្ឆិកា | សន្ទូចរនង | ៤៥០០០ ផ្លែ | ១៥០ | |
| | ខែ មករា ដល់ខែ កុម្ភៈ | សន្ទូចបង្កៃ | ១៥០០ ផ្លែ | ១.៥០០ | |
| | ខែមេសា ដល់ខែ ឧសភា | សំណាញ់ | ៣០ សំណាញ់ | ៣០ | |

### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្ដារបឹងដងទង់ | ៥០ x ៤០០ | ៥ x១៥០០ x១ម | -ស្ដារបឹង<br>-ប្រជាពលរដ្ឋចូលរួមកំណត់ចំនុច<br>-ជួលគ្រឿងចក្រមកជីក<br>-អាចម៍ដីដាក់ ផ្លូវ | ១/៤/ ០៨ | ៣០/៦/ ០៨ | |
| ស្ដារបឹងដងទង់ | ២០០x៧០០ | ៥០x១០០ x២ម | ដូចខាងលើ | ១/៤/ ០៩ | ៣០/៦/០៩ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងក្ដាក់ | ៧០x១០០ x១,៥ម | ត្រីមេពូជ | -បោះបង្គោលឈើព្វទ័ជុំវិញកន្លែងអភិរក្ស។<br>-ដាក់សំរះ -ដាក់ផ្លាកសញ្ញា<br>-ប៉មយាម -ទំលាក់លូសប្បនិម្មិត<br>-ចុះល្បាតជាប្រចាំ<br>- ផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋតាមរយៈប្រជុំភូមិ និងឃុំ<br>-គណៈកម្មការនិងក្រុមល្បាតចុះជួយធ្វើតំបន់អភិរក្ស | ១/២/ ០៨<br>១/៥/ ០៨ | ៣០/៤/ ០៨<br>៣០/៩/ ០៨ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក | ១ ហត | រាំង,ត្រស់និងផ្សេងៗទៀត | ដាំព្រៃលិចទឹក | ១/៦/០៨ | ១/៥/០៩ | |
| ២-ថែរក្សានិងរំលោះព្រៃលិចទឹកនៅចុងទូលត្របែក | ៥០x៤០០ម | ប្រភេទព្រៃលិចទឹកហើយអភិរក្ស | ផ្សព្វផ្សាយព្រៃលិចទឹក<br>-បោះស្លាកសញ្ញា<br>-ធ្វើតួបយាម | ១១/១២/០៨ | ៣០/៥/០៩ | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ ( ១៥x១០ម | ១១ ស្រះ | ឆ្ពិន ប្រា អណ្តែង | ១៥០០កូន | ខែ១២ឆ្នាំ ០៨ | ខែ ៨ ឆ្នាំ ០៩ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូល | ខែ ១១ ឆ្នាំ២០០៨ | ខែ១១ /ឆ្នាំ២០០៩ | ១៥០០០០៛ | |
| ភាគទានប្រចាំឆ្នាំ | ប្រមូល | ០១/៥/ឆ្នាំ២០០៩ | ៣០/៦/ឆ្នាំ២០០៩ | ២៥០០០០៛ | |
| ជំនួយពីអង្គការ PNKA | ប្រមូល | ០១/១/ឆ្នាំ២០០៨ | ៣០/១២/ឆ្នាំ២០០៩ | ៤០០០០០០៛ | |

## គ-៧ ផែនការចិញ្ចឹមសត្វ

ដោយយោងលើសហគមន៍នេសាទត្រូវការចាំបាច់ផងដែរនូវផលិតផលដែលបានមកពីការចិញ្ចឹមសត្វព្រោះសត្វទាំងនេះអាចផ្តល់នូវប្រាក់បន្ថែម និងជាអាហារផ្តល់ប្រូតេអ៊ីនដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ជួយកាត់បន្ថយភាពក្រីក្រ ។

ការចិញ្ចឹមសត្វនេះគណៈកម្មការសហគមន៍នេសាទមានផែនការសរសេរគម្រោងស្នើសុំទៅដល់ម្ចាស់ជំនួយផ្សេងៗដូចជាអង្គការ ហ្វាវ គំរោងទន្លេសាប រឺគម្រោងរដ្ឋាភិបាលជាដើម ។

***តារាងផែនការចិញ្ចឹមសត្វ***

| ប្រភេទសត្វចិញ្ចឹម | សកម្មភាព | គ្រួសារ | បរិមាណសត្វក្នុង១គ្រួសារ | បរិមាណសត្វសរុប | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| មាន់ | - បង្រៀនដល់សមាជិកពីការចិញ្ចឹម<br>-ផ្តល់ពូជញី ចំនួន៣ និងឈ្មោល១ក្បាលក្នុង ១គ្រួសារ<br>-សមាជិកថែរក្សា និងផ្តល់ចំណី<br>- តាមដានជំងឺសត្វ និងកត់ត្រា<br>-ពេលមានសត្វមាន់កូនត្រូវផ្តល់កូនញី ០៣ ឈ្មោល១ក្បាលដល់គ្រួសារផ្សេងទៀតដែលមិនទាន់បានចិញ្ចឹម<br>- សរសេរបាយការណ៍រៀងរាល់ខែ<br>- ទំនាក់ទំនងល្អជាមួយមន្ត្រីជំនាញ | ២៥ | ៤ ក្បាល | ១០០ | ១/១២/០៨ | ១/១២/១០ |
| ក្របី | - បង្រៀនដល់សមាជិកសហគមន៍នេសាទពីការចិញ្ចឹមគោ ដូចជាការផ្តល់ចំណី រោគសញ្ញានៃ ជម្ងឺ របៀបព្យាបាលដែលអាចធ្វើបានការថែទាំ និងការឱ្យ ចំណីជាដើម ។ -ផ្តល់ពូជញី ចំនួន១១ក្បាល និងឈ្មោល០១( បា)<br>-សមាជិកថែរក្សា និងផ្តល់ចំណី<br>- តាមដានជំងឺសត្វ<br>- សរសេរបាយការណ៍រៀងរាល់ខែ | ១២ | ១ ក្បាល | ១២ | ១/១២/០៨ | ១/១២/១០ |

| | | | | | | |
|---|---|---|---|---|---|---|
| | - ទំនាក់ទំនងល្អជាមួយមន្ត្រីជំនាញ<br>-ពេលបានកូនគោធំអាចបង្វិលទៅសមាជិកផ្សេងទៀត ។ | | | | | |
| ជ្រូក | - បង្រៀនដល់សមាជិកសហគមន៍នេសាទពីការចិញ្ចឹមជ្រូកដូចជាការផ្តល់ចំណី រោគសញ្ញានៃជម្ងឺ ការថែទាំ និងការឱ្យល់ចំណីជាដើម ។<br>-ផ្តល់កូនជ្រូកញី១ក្បាល និងឈ្មោល១ ( បា)<br>-សមាជិកថែរក្សា និងផ្តល់ចំណី<br>- តាមដានជំងឺសត្វ<br>-ពេលមានសត្វមានកូនត្រូវផ្តល់កូន២ រឺ៣ក្បាលដល់គ្រួសារផ្សេងទៀតដែលមិនទាន់បាន<br>- សរសេរបាយការណ៏រៀងរាល់ខែ ។ | ២០ | ១ ក្បាល | ២០ក្បាល | ១/១២/០៨ | ១/១២/១០ |

## គ-៤ ផែនការជីកស្រះចិញ្ចឹមត្រី

សហគមន៍នេសាទនឹងមានផែនការជីកស្រះចិញ្ចឹមត្រីបន្ថែមទៀត ដោយប្រើគ្រឿងចក្រ ហើយគណៈកម្មការសហគមន៍នេសាទមានផែនការសរសេរគម្រោងស្នើសុំទៅដល់ម្ចាស់ជំនួយផ្សេងៗដូចជាអង្គការ ហ្វាវ គំរោងទន្លេសាប រឺគម្រោងរដ្ឋាភិបាលជាដើម

***តារាងផែនការជីកស្រះចិញ្ចឹមត្រី***

| ប្រភេទ | សកម្មភាព | គ្រួសារ | បិមាណសត្វក្នុង១គ្រួសារ | បរិមាណសរុប | **ថ្ងៃខែឆ្នាំចាប់ផ្តើម** | **ថ្ងៃខែឆ្នាំបញ្ចប់** |
|---|---|---|---|---|---|---|
| ជីកស្រះ | ជីកស្រះចិញ្ចឹមត្រី ( ៨ x១០ x ៣ម) | ៦ | ១ស្រះ/គ្រួ | ៦ស្រះ | ១/៣/០៩ | ១/៤/០៩ |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈបង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៏នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដងទង់ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការកែលំអផែននេសាទ | -ស្តារបឹង ដងទង់<br>-ប្រជាពលរដ្ឋ ចូលរួមកំណត់ចំនុច<br>-ជួលគ្រឿងចក្រមកជីក | -បឹងជ្រៅនាំឱ្យមានទឹកសំបូរ<br>-សំបូរត្រី និងវារីជាតិ<br>-ជីវភាពប្រជាពលរដ្ឋមានការកើនឡើងវិញ។ | ១៤០០ ដុល្លា | គម្រោងរដ្ឋាភិបាល<br>-NGOs | ១/៤/ ០៨ | ៣០/៦/០៨ | |
| ២. ការកំណត់ និងរៀបចំតំបន់អភិរក្ស បឹងក្តាក់ | -បោះបង្គោលឈើព័ទ្ធជុំវិញ កន្លែងអភិរក្ស<br>-ដាក់ផ្លាកសញ្ញា -ប៉មយាម<br>-ទំលាក់លូសប្បនិម្មិត -ចុះល្បាតជាប្រចាំ<br>- ផ្សព្វផ្សាយទៅដល់ប្រជា ពលរដ្ឋតាមរយៈប្រជុំភូមិ និងឃុំ -គណៈកម្មការនិងក្រុមល្បាតចុះជួយធ្វើតំបន់អភិរក្ស | -សំបូរត្រី<br>-ជីវភាពកើនឡើង<br>-ប្រជាពលរដ្ឋមានការសប្បាយចិត្តដោយកំណត់កន្លែងច្បាស់លាស់ | ១០០០ ដុល្លា | គម្រោងរដ្ឋាភិបាល<br>រឺអង្គការក្រៅរដ្ឋាភិបាល | ១/២/ ០៨ | ៣០/៤/ ០៨ | |
| ៣-ផែនការគ្រប់គ្រង ព្រៃលិចទឹក | -ដាំព្រៃលិចទឹកនៅ បឹងក្តាក់<br>-ប្រជាជនចូលរួមដាំកូនឈើ<br>-សហគមន៏បណ្តុះកូនឈើ<br>-សិស្សសាលាចូលរួមដាំកូនឈើ<br>-ផ្សព្វផ្សាយប្រជាពលរដ្ឋ<br>-ដាក់ផ្លាកសញ្ញា | -សំបូរព្រៃ និងត្រី<br>-សំបូរសត្វស្លាប<br>-សំបូរសត្វល្អិតចាចំណីត្រី<br>-មានលំនឹងបរិស្ថាន | ៦០០ ដុល្លា | គម្រោងរដ្ឋាភិបាល<br>/FAO/<br>អង្គការក្រៅរដ្ឋាភិបាល.... | ខែ៨ ឆ្នាំ ២០០៨ | ខែ៩ ឆ្នាំ ២០០៩ | |
| ៤-ផែនការ អភិវឌ្ឍន៏វារីវប្បកម្ម *ចិញ្ចឹមត្រីក្នុងស្រះ* | -សរសេរគម្រោងស្នើរសុំទៅម្ចាស់ជំនួយ<br>-ជ្រើសរើសគ្រួសារដែលមាន ស្រះ<br>-ផ្តល់ពូជត្រីនិងបង្រៀនសមាជិក | -បង្កើនជីវភាព<br>-កាត់បន្ថយការនេសាទ<br>-មានការយល់ដឹងច្រើនពីសារៈ | ៦០០ ដុល្លា | គព្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប និងអង្គការនានា | ខែ១២ ឆ្នាំ ២០០៨ | ខែ ៨ឆ្នាំ ២០០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ពីបច្ចេកទេសចិញ្ចឹមត្រី<br>-តាមដានការងារចិញ្ចឹមទាំងផ្តល់ ចំណីក៏ដូចជាថែរក្សាគុណភាពទឹក ។<br>-សរសេរបាយការណ៍ និងវាយតម្លៃ<br>-កាត់៥០% នៃកូនត្រីដែលបានផ្តល់ឱ្យទៅគ្រួសារដែលចង់ចិញ្ចឹមបន្តទៀត | ប្រយោជន៍លើការចិញ្ចឹមត្រី | | | | | |
| ៥- ផែនការចិញ្ចឹមសត្វមាន់ ជ្រូក និងក្របី | -បង្រៀនដល់សមាជិកដែលទទួលការចិញ្ចឹម<br>-ផ្តល់ពូជញី និងឈ្មោលដល់គាត់<br>-សមាជិកថែរក្សា និងផ្តល់ចំណី<br>-តាមដានជំងឺសត្វ<br>-ពេលមានសត្វមាន់កូនត្រូវផ្តល់កូន រឺមេទៅកសិករផ្សេងៗទៀត ។<br>-សរសេរបាយការណ៍រៀងរាល់ខែ<br>-ទំនាក់ទំនងជាមួយអ្នកបច្ចេកទេស | -ប្រជាពលរដ្ឋមានចំណេះដឹងលើការចិញ្ចឹមសត្វ<br>-ប្រជាពលរដ្ឋមានជីវភាពកើនឡើង<br>-បានប្រាក់ចំណូលបន្ថែម<br>-ប្រជាជនមានសុវត្ថិភាពស្បៀង | ២០០០ ដុល្លា | គម្រោងរដ្ឋាភិបាល /FAO/ អង្គការក្រៅដូចជា PNKA រដ្ឋាភិបាល.... | ខែ១២ ឆ្នាំ ២០០៨ | ខែ១២ ឆ្នាំ ២០១០ | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | ផ្សព្វផ្សាយនិងពន្យល់ពីសារៈប្រយោជន៍នៃការប្រមូល និងសន្សំប្រាក់ទុកក្នុងសហគមន៍ ។ | សហគមន៍មានប្រាក់ដកល់ទុកសំរាប់ប្រើប្រាស់សំរាប់អភិវឌ្ឍន៍ជីវភាពរស់នៅ ។ | ១៥០ ដុល្លា | បានពីសមាជិកសហគមន៍ទាំងអស់ | ខែ១១ ឆ្នាំ ២០០៨ | ខែ ៦ ឆ្នាំ ២០០៩ | |
| ៧-ផែនការជីកស្រះពង្រីកចិញ្ចឹមត្រី | ជីកស្រះបន្ថែមចំនួន៦ស្រះ( ៨ x១០x ៣ម) សំរាប់ចិញ្ចឹមត្រី | -បង្កើនចំនួនស្រះបន្ថែមទៀត<br>-បង្កើនជីវភាពរស់នៅរបស់គាត់ | ១៧០០ ដុល្លា | គម្រោងរដ្ឋាភិបាល /FAO/ អង្គការក្រៅដូចជា WFP | ខែ៤ ឆ្នាំ ២០០៩ | ខែ ៤ ឆ្នាំ ២០១០ | |

| សកម្មភាព | ២០០៨ | | | | | | | | | | | | ២០០៩ | | | | | | | | | | | | ២០១០ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | |
| ២. ការកែលំអដែន នេសាទ | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | |
| ៤. ផែនការគ្រប់គ្រង ព្រៃលិចទឹក | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | |
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៦ ផែនការចិញ្ចឹមសត្វ | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៧. ប្រាក់ចំណូល | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក

លោកនាយ.....រដ្ឋបាលជលផល

**នាយសង្កាត់រដ្ឋបាលជលផល.........**

...........ថ្ងៃទី 11 ខែ 10 ឆ្នាំ ២០០8

លេខ :..................

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**បានឃើញ**

**មេឃុំ.........**

...............ថ្ងៃទី 11 ខែ 10 ឆ្នាំ ២០០8

លេខ : 3/77 ខខ

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

...........ថ្ងៃទី 27 ខែ 01 ឆ្នាំ ២០០8

**នាយអធិការដ្ឋាន រដ្ឋបាលជលផល.........**

.........ថ្ងៃទី 11 ខែ 10 ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ : 0285

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន រដ្ឋបាលជលផល.........

............ថ្ងៃទី 21 ខែ 10 ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល.........**